ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៥៧...អនក្រ

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារដើម្បីរៀបចំ សម្របសម្រួល និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទ តាមវិធីសាស្ត្រ "ចលនាភូមិថ្មី"

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- បានឃើញអនុក្រឹត្យលេខ៥១ អនក្រ.បក ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០១ ស្តីពីការធ្វើវិសោធនកម្មលើអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអភិវឌ្ឍន៍ជនបទ
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ១ .-**

ត្រូវបានបង្កើតក្រុមការងារដើម្បីរៀបចំ សម្របសម្រួល និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទ តាមវិធីសាស្ត្រ "ចលនាភូមិថ្មី" ដែលមានសមាសភាពដូចខាងក្រោម÷



www.pheakdeylaw.com

| | | |
|---|---|---|
| ១- ឯកឧត្តម **ជា សុផារ៉ា** | រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | ប្រធាន |
| ២- ឯកឧត្តម **ទង់ សណ្តាប់** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- ឯកឧត្តម **ស្ថាន ម៉ាណាន** | អនុរដ្ឋលេខាធិការក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| ៤- ឯកឧត្តម **ទេង ច័ន្ទសន្ធារ** | អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៥- លោក **តាត សុធា** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ | សមាជិក |
| ៦- លោក **ហួ គុលច័ន្ទ** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍សហគមន៍ | សមាជិក |
| ៧- កញ្ញា **នូសុចត្ថិ ចាន់ចត្តី** | សមាជិកខុទ្ទកាល័យរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ | លេខាធិការ។ |

**ប្រការ២ .-**

ក្រុមការងារដើម្បីរៀបចំ សម្របសម្រួល និងអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទ តាមវិធីសាស្ត្រ "ចលនាភូមិថ្មី" មានតួនាទីជាសេនាធិការជូនរាជរដ្ឋាភិបាលក្នុងការរៀបចំនិងសម្របសម្រួលការអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទ ក្នុងលក្ខណៈជាប្រព័ន្ធនិងជាខ្សែចង្វាក់ប្រទាក់ក្រឡាគ្នា។

ក្រុមការងារនេះ មានភារកិច្ចដូចខាងក្រោម÷

- រៀបចំគោលនយោបាយអភិវឌ្ឍន៍ជនបទនៃព្រះរាជាណាចក្រកម្ពុជា តាមវិធីសាស្ត្រ "ចលនាភូមិថ្មី" ដោយសហការជាមួយអ្នកជំនាញនៃព្រះរាជាណាចក្រកម្ពុជានិងអ្នកជំនាញនៃសាធារណរដ្ឋកូរ៉េ ឱ្យមានសង្គតិភាពជាមួយគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលនិងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា
- រៀបចំគម្រោងនិងជ្រើសរើសទីតាំងភូមិសាស្ត្រសមស្រប សម្រាប់ធ្វើការអនុវត្តសាកល្បងនូវគោលនយោបាយអភិវឌ្ឍន៍ជនបទ តាមវិធីសាស្ត្រ "ចលនាភូមិថ្មី"
- សម្របសម្រួលការអនុវត្តគម្រោងអភិវឌ្ឍន៍ស្របតាមគោលនយោបាយ ផែនការ និងទីតាំងភូមិសាស្ត្រដែលបានជ្រើសរើស
- ផ្សព្វផ្សាយព័ត៌មាន ដើម្បីជំរុញលើកទឹកចិត្តឱ្យប្រជាពលរដ្ឋឱ្យស្វែងយល់អំពីទស្សនៈរបស់ "ចលនាភូមិថ្មី" និងចូលរួមអនុវត្តគោលនយោបាយអភិវឌ្ឍន៍ជនបទ តាមវិធីសាស្ត្រ "ចលនាភូមិថ្មី"
- កៀរគរថវិកានិងទាក់ទាញឱ្យមានការចូលរួមវិនិយោគពីវិស័យឯកជននិងដៃគូអភិវឌ្ឍនៅក្នុងការអនុវត្តគម្រោង
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល
- ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលរាជរដ្ឋាភិបាលប្រគល់ជូន។

**ប្រការ៣ .-**

ក្រុមការងារត្រូវធ្វើការប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ។

ប្រធានក្រុមការងារអាចអញ្ជើញតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល តំណាងដៃគូអភិវឌ្ឍ និងអ្នកជំនាញពាក់ព័ន្ធចូលរួមប្រជុំតាមការចាំបាច់។



www.pheakdeylaw.com

**ប្រការ៤ .-**

ក្រុមការងារប្រើប្រាស់ត្រារបស់ក្រសួងអភិវឌ្ឍន៍ជនបទ ក្នុងការចាត់ចែងការងាររបស់ខ្លួន។

**ប្រការ៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមីនា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com